# សេចក្តីប្រកាសព័ត៌មាន

## ពិធីបើកសម្ពោធការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ ជាស្ថាប័នអន្តរជាតិ

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ២០១៦ កម្មវិធីបើកសម្ពោធការប្រែក្លាយការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ទៅជាស្ថាប័នអន្តរជាតិត្រូវបានប្រារព្ធឡើងជាផ្លូវការ ។

ពិធីនេះមានការចូលរួមពីតំណាងធនាគារកណ្តាលនិងក្រសួងហិរញ្ញវត្ថុនៃប្រទេសសមាជិកអាស៊ាន+៣ ស្ថាប័នអន្តរជាតិ ស្ថានទូតប្រចាំប្រទេសសិង្ហបុរី ស្ថាប័នហិរញ្ញវត្ថុឯកជន និងស្ថាប័នស្រាវជ្រាវសេដ្ឋកិច្ចនានា ។

គួររំលឹកថា ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ ត្រូវបានបង្កើតឡើងកាលពីឆ្នាំ ២០១១ ក្នុងក្របខណ្ឌគតិយុត្តជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់នៅប្រទេសសិង្ហបុរី ដើម្បីលើកកម្ពស់ការតាមដាន និងឃ្លាំមើលស្ថានភាពសេដ្ឋកិច្ចប្រចាំតំបន់ ។ នៅខែតុលា ឆ្នាំ២០១៤ សមាជិកអាស៊ាន+៣ បានចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងមួយ ដែលប្រែក្លាយការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ ទៅជាស្ថាប័នអន្តរជាតិ ហើយកិច្ចព្រមព្រៀងនេះបានចូលជាធរមាននៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៦ ។ ការប្រែក្លាយនេះនឹងធ្វើឲ្យការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ បំពេញតួនាទីរបស់ខ្លួនកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ក្នុងនាមជាអង្គភាពឃ្លាំមើលសេដ្ឋកិច្ចឯករាជ្យក្នុងតំបន់ សំដៅរួមចំណែករក្សាស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់។

ក្នុងពិធីសម្ពោធនោះ លោកបណ្ឌិត Yoichi Nemoto ប្រធាន AMRO បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សមាជិកអាស៊ាន+៣ ដែលបានគាំទ្រចំពោះការប្រែក្លាយខ្លួនទៅជាស្ថាប័នអន្តរជាតិ ព្រមទាំងបានបង្ហាញពីការប្តេជ្ញាចិត្តរបស់លោកក្នុងការបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹងសកម្មភាពឃ្លាំមើល និងការគាំទ្រលើការអនុវត្តកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ។